00833769

E1/106.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Aug-2012, 16:00
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅជំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២**

**ម៉ោង ០៩:២៤ នាទី**

**សវនាការលើកទី៩៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

លោក ដាវ អានសាន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាវស្នី

លោក វេង ហ៊ត់

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក ហ្វែឌីណង់ ចាមិន ហ្សេប៉ា
*(Mr. Ferdinand DJAMMEN NZEPA)*

លោកស្រី ស៊ីន សុវ៉ន

លោក ឡោ ជុនធី

លោកស្រី បេនី យេ (*Ms. Beini YE)*

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក គឹម សមសាន្ត (វេជ្ជបណ្ឌិត) | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:២៥:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ តាមកម្មវិធីកាលវិភាគនៃកិច្ចដំណើរការសវនាការដែលបានគ្រោងទុក គឺបន្តការតាំងសំណួរដេញដោលចំពោះសាក្សី សួង ស៊ីគឿន ហើយនិងសាក្សី អុង ថុងហឿង អាចលទ្ធភាពផ្លាស់គ្នា ដោយការសួរដេញដោលពីសំណាក់ក្រុមមេធាវីការពារក្តី។

មុននឹងចាប់ផ្តើមកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោល លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

[០៩:២៦:២១]

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ។ ជនជាប់ចោទ អៀង សារី តាមរយៈមេធាវីរបស់គាត់បានស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះសម្រាប់រយៈពេលពេញ១ថ្ងៃនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ អៀង សារី បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សី សួង ស៊ីគឿន មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ ចំពោះសាក្សី អុង ថុងហឿង នឹងមានវត្តមាននៅជំនុំជម្រះនៅម៉ោងដប់ម្ភៃនាទី។

សូមអរគុណលោកប្រធាន។

[០៩:២៧:១៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៤:០៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ មេធាវីការពារលោក អៀង សារី មូលហេតុដែលៗយើងប្រើពេលពិភាក្សានេះទាក់ទងទៅនឹងសំណើរបស់លោកនោះ គឺថាយើងបានទទួលនូវសំបុត្របញ្ជាក់ពីវេជ្ជបណ្ឌិតថា លោក អៀង សារី មានការវិលមុខ ហើយមិនអាចផ្ដង់អារម្មណ៍បាន។ អ៊ីចឹងថាតើលោកបានដឹងពីរឿងហ្នឹងដែរហើយឬនៅ មុននឹងធ្វើសំណួរដើម្បីឲ្យគាត់នៅបន្ទប់ខាងក្រោមនេះ?

មេធាវី -- ហើយមេធាវី -- បាទ លោកវេជ្ជបណ្ឌិតគាត់ដឹងពីបញ្ហានេះ។

[០៩:៣៤:៥៨]

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោក លោកស្រីចៅក្រម សូមជម្រាបសួរភាគីទាំងអស់ និងសាធារណជន។ លិខិតលះបង់សិទ្ធិគឺថាយើងបានដាក់ជូនទៅតុលាការ មុនពេលដែលយើងបានជួបលោក អៀង សារី ហើយខ្ញុំបានជួបៗគាត់ប្រហែលជា២០ ទៅ២៥មីនុត។ ហើយនៅពេលដែលយើងបានដាក់ជូនលិខិតនេះ គឺថាគាត់មានសុខភាពធម្មតា ប៉ុន្តែក្រោយមក នៅក្នុងការសន្ទនារបស់ខ្ញុំជាមួយគាត់ គាត់បានបញ្ជាក់ថាគាត់វិលមុខខ្លាំង នៅតាមដានមិនបាន ហើយអស់កម្លាំងខ្លាំង ដែលសូមជម្រាបឲ្យតុលាការបានជ្រាបថា សូមឲ្យវេជ្ជបណ្ឌិតពិនិត្យគាត់ឡើងវិញ។ ដូច្នេះហើយដែលថា ព័ត៌មានថ្មីដោយជាក់ស្ដែងនោះ គាត់មិនបោះបង់សិទ្ធិចំពោះការចូលរួមវត្តមាននោះទេ ប៉ុន្តែគាត់ចង់ចូលរួមពីបន្ទប់នៅខាងក្រោម។ ប៉ុន្តែទាក់ទងទៅនឹងដើម្បីឲ្យបានច្បាស់អំពីបញ្ហានេះ ហើយចំពោះសាក្សីផ្សេងៗទៀត យើងយល់ថា យើងមានការបត់បែនបាន ថាលោក អៀង សារី គឺថាអាចនឹង -- ហើយចំពោះសាក្សីបន្ទាប់ ឬក៏តាមសាក្សីដែលយើងដឹងថ្ងៃនេះ គាត់មិនចង់បោះបង់សិទ្ធិគាត់ទាំងអស់ទេ។ ហើយយើងគិតថា ប្រសើរបំផុត គឺគាត់អាចផ្ដង់អារម្មណ៍ ហើយអាចជួយដល់យើងខ្ញុំបាន ពីព្រោះថា យើងបានផ្ដល់ការណែនាំរបស់យើង ហើយយើងបានទាក់ទងជាមួយគាត់ជាបន្ត។ សូមអរគុណបាទ។

**ប្រធានអង្គជំនុំ៖**

បាទ មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញលោកគ្រូពេទ្យ កឹម សមសាន្ត ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះ អំពីបញ្ហាសុខភាពលោក អៀង សារី នៅព្រឹកនេះ។

បាទ សួស្តីលោកវេជ្ជបណ្ឌិត។ ទីមួយ គឺលោកសូមលោកប្រាប់ដល់អង្គជំនុំជម្រះអំពីនាមត្រកូល នាមខ្លួន អាយុ ហើយមុខងារបច្ចុប្បន្នរបស់លោកនៅក្នុងមន្ទីពេទ្យរដ្ឋ ហើយនិងបំពេញបេសកកម្មបន្ថែម នៅ អ.វ.ត.ក។

**លោក គឹម សមសាន្ត៖**

បាទ ជម្រាបសួរ! សូមជម្រាបសួរអង្គជំនុំជម្រះទាំងមូល។ ខ្ញុំបាទ វេជ្ជបណ្ឌិត គឹម សមសាន្ត អាយុ៤៧ឆ្នាំ ធ្វើការនៅមន្ទីរពេទ្យព្រះបាទ -- មន្ទីរពេទ្យមិត្តកម្ពុជាសូវៀត។ ខ្ញុំបាទធ្វើការក្នុងរយៈពេល តាំងពីឆ្នាំ១៩៩១ រហូតដល់បច្ចុប្បន្ន។ បច្ចុប្បន្ននេះ ធ្វើការនៅផ្នែកជំងឺទូទៅ ហើយនិងមានភារកិច្ចបន្ថែម មួយទៀត មកតាមដានជំងឺនៅក្នុង អ.វ.ត.ក នេះបាទ។

[០៩:៣៨:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកអាចជម្រាបដល់អង្គសវនាការបានទេ អំពីការពិនិត្យមើលរបស់លោក ចំពោះបញ្ហាសុខភាពរបស់លោក អៀង សារី កាលពីព្រឹកមិញនេះ។ ហើយតើគាត់មានអាការៈយ៉ាងដូច ម្តេចខ្លះ ដែលលោកបានកត់សម្គាល់ឃើញ? ហើយលោកក្នុងនាមជាអ្នកទទួលបន្ទុកថែទាំសុខភាពជន ជាប់ចោទ នៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក តើលោកផ្តល់អនុសាសន៍យ៉ាងម៉េចៗខ្លះ ចំពោះដំណើរការ ប្រព្រឹត្តទៅ ក្នុងកិច្ចដំណើរការសវនាការសម្រាប់ព្រឹកនេះ?

**លោក គឹម សមសាន្ត៖**

ខ្ញុំបានពិនិត្យស្ថានភាពជំងឺរបស់គាត់ពីរដង។ លើកទី១ នៅម៉ោងប្រាំបីដប់ប្រាំនាទី ការពិនិត្យនៅ លើកទី១នេះ បង្ហាញថា រោគសញ្ញាស៊ីងសំខាន់ៗរបស់គាត់ទាំងអស់ នៅមានលំនឹង។ ប៉ុន្តែអ្វីដែលប្លែក គឺគាត់នោមច្រើន ក្នុងព្រឹកហ្នឹង។ បានន័យថា គាត់ក្រោកទៅនោមច្រើនដង ខុសពីថ្ងៃមុនៗ។ នៅពេល នុំង ខ្ញុំបានផ្តល់អនុសាសន៍ថា គាត់គួរតែ -- អង្គសវនាការអនុញ្ញាតឲ្យគាត់សម្រាកស្តាប់ចូលរួមអង្គ សវនាការនៅបន្ទប់ខាងក្រោម។ ប៉ុន្តែនៅម៉ោងប្រាំបួនដប់នាទី គាត់មានបញ្ហាមួយទៀត នៅពេលដែល ខ្ញុំទៅជួបគាត់ៗឃើញថាគាត់ពិតជាក្រោកទៅនោមញឹកមែន ប៉ុនហើយការដែលគាត់នោមញឹកនេះហើយ ដែលធ្វើឲ្យគាត់អស់កម្លាំង គាត់វិលមុខ។ ទន្ទឹមនឹងនោះ គាត់បានប្រាប់ខ្ញុំថាអារម្មណ៍របស់គាត់ហាក់ ដូចជាប្លែកខុសសព្វដង ការចងចាំរបស់គាត់ធ្លាក់ចុះ។ ដូច្នេះ គាត់គិតថា គាត់មិនអាចចូលរួមស្តាប់ នៅក្នុងសវនាការហ្នឹងបានទេ។ ហើយចំពោះអាការៈចងចាំនេះ ខ្ញុំមិនអាចមានលទ្ធភាពវាយតម្លៃបានទេ

ព្រោះអានេះជារោគសញ្ញាដែលគាត់និយាយប្រាប់យើងតែប៉ុណ្ណឹងឯងបាទ។

[០៩:៤១:២៨]

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម មានសំណួរអីចង់សួរដល់បញ្ជាក់បន្ថែមចំពោះលោកវេជ្ជបណ្ឌិតរូបនេះទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណលោកប្រធាន។ លោកវេជ្ជបណ្ឌិតថាតើផ្នែកវេជ្ជសាស្ត្រព្យាបាល តើមានការប្រែប្រួលរវាងការពិនិត្យព្រឹកមិញលើកទី១ ហើយនិងទី២ ហ្នឹងមានភាពខុសគ្នាដែរឬទេ? តើលោកៗបានទទួលការកត់សម្គាល់ពីលោក អៀង សារី តើ ក៏ប៉ុន្តែសម្រាប់លោកផ្ទាល់នោះ តើចំពោះលោកនោះតើលោកសង្កេតឃើញមានចំណុចណា កត្តាណាមួយទេ ឬក៏រកមិនមានឃើញ មានការប្រែប្រួលសម្គាល់ឈាមទេ? មានការប្រែប្រួលផ្សេងទៀត ដែលលោកអាចរៀបរាប់ជូនតុលាការទេ? ឬក៏ពុំមានរោគសញ្ញាណាមួយដែលគាំទ្រនូវការកត់សម្គាល់របស់លោក អៀង សារី ដែលថាខ្លួនមិនស្រួលខ្លួននោះមានបញ្ហាសុខភាព?

[០៩:៤២:៣៩]

**លោក គីម សមសាន្ត៖**

អ្វីដែលប្លែកខុសពីសព្វដងនោះ គឺគាត់ក្រោកទៅនោមញឹកខុសពីធម្មតា។ លក្ខណៈនោមញឹកនេះជាគំនិតរបស់ខ្ញុំ គឺថាគាត់ ដោយសារការដែលគាត់នោមញឹកនេះហើយ ធ្វើឲ្យគាត់ក្រោកៗគាត់ចំណាយថាមពលច្រើន ហើយដោយសារគាត់មានជំងឺដូច្នេះ ធ្វើឲ្យគាត់វិលមុខ។ ព្រោះជំងឺគាត់មិនអាចចំណាយថាមពលច្រើនបានទេ ដោយសារជំងឺបេះដូងរបស់គាត់។ ហើយនិងលក្ខណៈប្លែកមួយទៀតហ្នឹងគឺដូចខ្ញុំជម្រាបអ៊ីចឹង ម៉ោងប្រាំបួនដប់ប្រាំនាទី -- ដប់នាទីហ្នឹង ដែលគាត់ត្អូញថា គាត់អារម្មណ៍របស់គាត់ពេលនេះគឺអស់កម្លាំងខ្លាំង វិលមុខ ហើយអារម្មណ៍ច្របូកច្របល់ គាត់មិនអាច -- គាត់ភ្លេចភ្លាំងច្រើន។ ដូច្នេះគាត់និយាយថា គាត់មិនអាចស្ដាប់សវនាការហ្នឹងបាន។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំយល់ហើយលោកវេជ្ជបណ្ឌិត គឺថាមាន គឺថាលោក អៀង សារី គាត់និយាយថា គាត់វិល

មុខ ក៏ប៉ុន្តែលោកផ្ទាល់ លោកជាវេជ្ជបណ្ឌិតនោះ តើលោកបានកត់សម្គាល់សញ្ញាគ្លីនិក ដែលគាំទ្រថាមានវិលមុខមែនឬទេ? លោក អៀង សារី វិលមុខដែរឬទេ? ឬបើតាមលោកសង្កេតផ្ទាល់នោះ តើមានរោគសញ្ញាណាបង្ហាញថាវិលមុខទេ? ហើយចំពោះការពិនិត្យរបស់លោកផ្ទាល់នោះ តើលោកទាញការសន្និដ្ឋានបែបណាដែរ? គឺថាទាញការសន្និដ្ឋានថាជនជាប់ចោទអាចចូលរួមសវនាការនេះ ឬក៏អត់នៅនៅថ្ងៃនេះ? តើគាត់អាចចូលរួមពីបន្ទប់ខាងក្រោមនោះបាន ឬក៏ពីនៅក្នុងបន្ទប់ជំនុំជម្រះនេះផ្ទាល់តែម្តងបានដែរឬទេ? នេះជាសំណួរខ្ញុំ។

**លោក គឹម សមសាន្ត៖**

ចំពោះខ្ញុំលទ្ធភាពវាយតម្លៃស្ថានភាពគាត់នៅពេលដំបូងហ្នឹង បង្ហាញថាគាត់ពិតជាវិលមុខមែន។ ហើយអ្វីដែលយើងអះអាងថា គាត់វិលមុខហ្នឹង គឺនៅពេលដែលគាត់ក្រោកឈរទៅនោមម្តងៗ គឺដំណើរគាត់តេះតះ ហើយនៅពេលគាត់នោម គាត់ត្រូវទប់គ្រែហ្នឹង បើមិនទប់ទេ គាត់ត្រូវដួល។ បាទ ហើយក្រោយពីគាត់នោម ហើយ គាត់ត្រូវចូលទៅសម្រាកវិញ។ នៅពេលដែលគាត់សម្រាកហ្នឹង គាត់ដង្ហើមគាត់ក៏ញាប់ខុសពីធម្មតា ហើយគាត់ហត់និយាយដាច់ៗ។ បាទ ត្រង់នេះហើយ ជាសញ្ញាបញ្ជាក់ថាភាពវិលមុខហ្នឹង ពិតជាមាន -- ពិតជាកើតមានទៅលើរូបគាត់មែន។ ចំណែកឯការភ្លេចភ្លាំងដែលគាត់និយាយនុ៎ង។ ខ្ញុំមិនអាចធ្វើការសន្និដ្ឋានបានទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

អ៊ីចឹង តើការសន្និដ្ឋានរបស់លោកហ្នឹង គឺថាជនជាប់ចោទនោះត្រូវការសម្រាកនៅថ្ងៃនេះ អ៊ីចឹងមែនទេ?

**លោក គឹម សមសាន្ត៖**

ចំពោះបញ្ហាសុខភាពផ្លូវកាយរបស់គាត់ ការសម្រាកនៅបន្ទប់ខាងក្រោម ដើម្បីស្តាប់សវនាការហ្នឹង វាសមស្របហើយ។ ប៉ុន្តែចំពោះការដែលគាត់ស្តាប់ ហើយដែលគាត់និយាយថា គាត់ស្តាប់មិនបាន ស្តាប់មិនយល់ នោះខ្ញុំគិតថា ការធ្វើសវនការហ្នឹងក៏វា -- ប្រហែលជាមិនមានប្រយោជន៍អីដែរ ព្រោះគាត់ថា សវនាការនៅពេលនេះសំខាន់ណាស់ គាត់ចង់ស្តាប់ឲ្យបានយល់ ១០០ភាគរយ។

[០៩:៤៦:៤៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥០:២៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកគ្រូពេទ្យ។ លោកគ្រូពេទ្យអាចអញ្ជើញត្រឡប់ទៅកាន់ទីកន្លែងវិញហើយ។

បាទ ឥឡូវនេះកិច្ចដំណើរការសវនាការពិភាក្សាដេញដោល ស្តាប់សក្ខីកម្មសាក្សីដែលបានគ្រោងទុកហ្នឹងគឺ សួង ស៊ីគឿង មិនអាចដំណើរការបានទេនៅព្រឹកនេះ ដោយសារមូលហេតុលោក អៀង សារី មានបញ្ហាសុខភាព។

[០៩:៥១:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥២:២៧]

**ប្រធានអង្គជំនុំ៖**

បាទ តាមកិច្ចពិភាក្សាអង្គជំនុំជម្រះមានបំណងផ្អាកកិច្ចដំណើរការសវនាការព្រឹកនេះ ដោយមូលហេតុបញ្ហាលោក អៀង សារី គាត់មានបញ្ហាសុខភាព គាត់វិលមុខ ហើយគាត់ភ្លេចភ្លាំងច្រើន មិនអាចចងចាំបាន ហើយគាត់នៅតែទទូចសុំសិទ្ធិនៅក្នុងការចូលរួមស្តាប់សក្ខីកម្មសាក្សីចំនួនពីររូបដែលពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធនៃក្រសួងការបរទេស គឺបេ-១ នេះ។ ហើយ តើភាគីផ្សេងៗនៅក្នុង -- នៃរឿងក្តីនេះមានមតិយោបល់អ្វីទេចំពោះបញ្ហានេះ?

សូមអញ្ជើញលោកមេធាវី!

**លោក សុន អរុណ៖**

តាមយោបល់ខ្ញុំជាក្រុមមេធាវីការពារលោក នួន ជា ខ្ញុំយល់ថាការស្តាប់មិនបាន យល់ -- ហើយមិនយល់នៅសវនាការនេះ ទោះបីឲ្យគាត់នៅក្នុងបន្ទប់ក្រោមក៏ដោយ ការស្តាប់មិនបានហ្នឹងទុកជាអត់បានការ។ ហើយបើមិនអ៊ីចឹងទេ ខ្ញុំថាគួរតែសម្រាកតាមយោបល់ចៅក្រម ខ្ញុំគាំទ្រក្នុងព្រឹកនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ដូច្នេះទេ បើមិនមានមតិយោបល់ទេ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការព្រឹកនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅរសៀលនេះ ចាប់ផ្តើមវេលាម៉ោងមួយសាមសិបនាទី ដោយកំណត់នូវរបៀបវារៈនៃកិច្ចពិភាក្សាដេញដោលគឺដដែល។ គឺបន្តស្តាប់សក្ខីកម្មសាក្សី សួង ស៊ីគឿន ដោយក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដែលនឹងបន្តបញ្ចប់ដោយក្រុមមេធាវីការពារក្តីអន្តរជាតិ។

ហើយអនុរក្សមន្ទីរឃុំឃាំងនាំលោក នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោម ហើយនិងនៅរសៀលនេះឲ្យនាំគាត់មកកាន់បន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ០៩:៥៥ នាទី ដល់ម៉ោង ១៣:៤៤ នាទី)*

[១៣:៤៤:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះសូមជម្រាបជូន -- សូមប្រកាសបើកសវនាការ ហើយនិងសូមជម្រាបជូនដល់ភាគី និងសាធារណជនឲ្យបានជ្រាបថា អំពីបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី កាលពីព្រឹកមិញ គឺអង្គជំនុំជម្រះបានស្តាប់នូវសេចក្តីរាយការណ៍អំពីគ្រូពេទ្យ កឹម សមសាន្ត ដែលទទួលបន្ទុកពិនិត្យថែទាំសុខភាពជនជាប់ចោទនៅក្នុងមន្ទីរឃុំឃាំង នៃអ.វ.ត.ក បានបង្ហាញហើយថា ជនជាប់ចោទមានអាការៈវិលមុខខ្លាំង មិនអាចស្តាប់អង្គសវនាការបាន ហើយមានការភ្លេចភ្លាំងច្រើន មិនអាចចងចាំបាន។ ហើយអង្គជំនុំជម្រះ បានសម្រេចលើកសវនាការមកបន្តធ្វើនៅរសៀលនេះ ដោយសាររង់ចាំមើលស្ថានភាពជាក់ស្តែង នៃបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី ហើយរហូតដល់អម្បាញ់មិញនេះ គឺវេលាម៉ោងមួយដប់នាទី លោកគ្រូពេទ្យ កឹម សមសាន្ត ក៏បានពិនិត្យអាការៈសុខភាពជនជាប់ចោទ អៀង សារី គឺគាត់នៅតែវិលមុខ និងហត់ខ្លាំង ហើយជាពិសេសនៅពេលក្រោកនោម ហើយនិងនោមច្រើន ហើយហូបអាហារថ្ងៃត្រង់មិនបាន និងសម្រាន្តមិនលក់ មានអារម្មណ៍ច្របូកច្របល់ ហើយលោកគ្រូពេទ្យបានផ្តល់អនុសាសន៍ថា សុខភាពរបស់លោក អៀង សារី នៅរសៀលនេះ មិនមានអ្វីប្រសើរជាងពេលព្រឹកនោះទេ។

[១៣:៤៧:០០]

ហើយផ្តល់អនុសាសន៍ថា គប្បីអនុញ្ញាតឲ្យគាត់សម្រាក មិនឲ្យគាត់ចូលរួមសវនាការទេ ដោយយោងទៅនឹងបទប្បញ្ញត្តិនៃវិធានដែលអនុវត្តនៅអ.វ.ត.ក នេះ អង្គជំនុំជម្រះត្រូវដំណើរការជំនុំជម្រះក្តីដោយចំពោះមុខជនជាប់ចោទ ទោះបីករណីណាក៏ដោយ ចំពោះមុខដោយនៅក្នុងសវនាការដោយផ្ទាល់

ឬក៏យ៉ាងហោចណាស់ គឺអាចស្តាប់សក្ខី-- ស្តាប់តាមដានកិច្ចដំណើរការសវនាការដេញដោលពីបន្ទប់ខាងក្រោម តាមរយៈប្រព័ន្ធសោតទស្សន៍។ ប៉ុន្តែដោយសារបញ្ហាសុខភាពរបស់គាត់ គាត់មានអារម្មណ៍ច្របូកច្របល់ ហើយភ្លេចភ្លាំងច្រើន មិនអាចដំណើរការបាន។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចធ្វើសវនាការបានទេនៅរសៀលនេះ។

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ដូចសព្វថ្ងៃ ដូចរាល់ដង។ ហើយនៅថ្ងៃស្អែកនេះ គឺអង្គជំនុំជម្រះមានបំណងស្តាប់សក្ខីកម្មសាក្សី អ៊ុង ចុងហឿង ជាមុន ប្រសិនបើអាចដំណើរការបាន ដោយហេតុថា សាក្សីរូបនេះ គាត់ត្រូវពេលវេលាគាត់អញ្ជើញមកកម្ពុជានេះ ត្រូវវិលត្រឡប់ទៅប្រទេសដែលគាត់រស់នៅ នៅឯអឺរ៉ុបវិញ ដោយបញ្ហាសំបុត្រយន្តហោះមិនអាចពន្យារពេលបាន។ ហើយទន្ទឹមនេះដែរ គឺអង្គជំនុំជម្រះពិនិត្យលទ្ធភាពក្នុងការស្តាប់សក្ខីកម្មសាក្សី សួង ស៊ីគឿន ដែលជាសាក្សីមួយរូបដែលយើងបានកំណត់ក្នុងការដេញដោលសវនាការនៅថ្ងៃនេះដែរ។ ប៉ុន្តែដោយសារសារៈសំខាន់នៃបញ្ហាសាក្សីពីរនេះ មានស្ថានភាពខុសគ្នា ប្រសិនបើអាចធ្វើបាន អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី អ៊ុង ចុងហឿង មុន។

[១៣:៤៩:០៨]

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ ហើយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ទៅកាន់មន្ទីរឃុំឃាំង នៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំខ្លួនពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ហើយដោយឡែកមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលក្នុងការជូនសាក្សីទាំងពីររូប វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែង -- មកកាន់បន្ទប់សវនាការនេះវិញនៅថ្ងៃស្អែក គឺលោក អ៊ុង ចុងហឿង នៅវេលាម៉ោងប្រាំបួនព្រឹក។ ហើយដោយឡែកសាក្សី សួង ស៊ីគឿន រក្សាទុកនៅទីកន្លែងបម្រុងទុកនៅក្នុងបរិវេណ អ.វ.ត.ក នេះ ដើម្បីត្រៀមផ្តល់សក្ខីកម្មបន្តពីសក្ខីកម្មរបស់លោក អ៊ុង ចុងហឿង បានចប់។

អង្គជំនុំជម្រះប្រកាសសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៣:៥០ នាទី)*